## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

មាត្រា ១៥ .— សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច_ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន និងអភិបាលខេត្ត_ក្រុងទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថ លេខានេះតទៅ ។

**នាយករដ្ឋមន្ត្រីទី ១** **នាយករដ្ឋមន្ត្រីទី ២**

**ព្រះហស្តលេខា និងត្រា** **ហត្ថលេខា និង ត្រា**

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៦

## អនុក្រឹត្យ លេខ : ១១ អនក្រ.បក

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងសំរាប់សំណង់វារីអគ្គិសនីស្ទឹងមេទឹក (មណសាម) នៃព្រះរាជាណាចក្រកម្ពុជា

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- យោងតាមព្រះរាជក្រឹត្យលេខ ន.ស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងតាមព្រះរាជក្រឹត្យលេខ ន.ស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– តាមសំណើរបស់អង្គប្រជុំអន្តរក្រសួងស្តីពីគំរោងស្ថាបនាវារីអគ្គិសនីលើស្ទឹងមេទឹក (មណាម) នាថ្ងៃ ទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**សំរេច**

**មាត្រា ១** : បង្កើតគណៈកម្មការអន្តរក្រសួងមួយមានឈ្មោះថា :«គណៈកម្មការវារីអគ្គិសនីស្ទឹងមេទឹក(មណាម) នៃព្រះរាជាណាចក្រកម្ពុជា «ហៅកាត់ថា «គ.វ.ក» ។

**មាត្រា ២** : គណៈគណៈកម្មការវារីអគ្គិសនីស្ទឹងមេទឹក (មណាម) មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១–ឯកឧត្តម **អ៊ឹង គៀត** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | សហប្រធាន |
| ២–ឯកឧត្តម **ឡៅ ឃាញ់** | សហរដ្ឋមន្ត្រីក្រសួងការពារជាតិ | សហប្រធាន |
| ៣–ឯកឧត្តម **សុខ អាន** | សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤–ឯកឧត្តម **វ៉េង សេរីវុឌ្ឍ** | សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥–ឯកឧត្តម **ម៉ុក ម៉ារ៉េត** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៦–ឯកឧត្តម **ពូ សុធីរៈ** | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល | សមាជិក |
| ៧–ឯកឧត្តម **តាវ សេងហួរ** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ៨–ឯកឧត្តម **អ៊ុច គីមអន** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩–ឯកឧត្តម **អ៊ឹម ឈុនលឹម** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១០–ឯកឧត្តម **ស៊ុន ចាន់ថុល** | អគ្គលេខាធិការក្រុមប្រឹក្សា | |

| | | |
|---|---|---|
| | អភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១១-ឯកឧត្តម **ឆាយ ថន** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |

**មាត្រា ៣** : គណៈកម្មការវារីអគ្គិសនីស្ទឹងមេទឹក (មណាម) ត្រូវបានអនុញ្ញាតអោយមានក្រុមការងារជាអ្នកឯកទេស សំរាប់ជួយរាល់កិច្ចការពាក់ព័ន្ធ និង គំរោងស្ថាបនាវារីអគ្គិសនីនេះដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម **ឃី តាំងលីម** | អនុប្រធានគណៈកម្មការជាតិទន្លេមេគង្គ | ប្រធាន |
| ២-ឯកឧត្តម **លីម គានហោ** | អគ្គនាយកធារាសាស្ត្រ | អនុប្រធាន |
| ៣-លោក **អ៊ុង ទ័ន** | អភិបាលរងខេត្តកោះកុង | សមាជិក |
| ៤-លោក **ធីក គ្រឿងវុឌ្ឍា** | ទីប្រឹក្សាក្រសួងមហាផ្ទៃ | សមាជិក |
| ៥-វរៈសេនីយ៍ឯក **ម៉ែត នរិទ្ធ** | នាយករង នាយកដ្ឋានវិស្វកម្មនៃក្រសួងការពារជាតិ | សមាជិក |
| ៦-លោក **សយ សុខា** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧-លោក **សុខ សារ៉ាន** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨-លោក **ប៊ុន ណារិទ្ធិ** | តំណាងក្រសួងឧស្សាហកម្មរ៉ែនិងថាមពល | សមាជិក |
| ៩-លោក **អ៊ុង គិរុន** | តំណាងក្រសួងបរិស្ថាន | សមាជិក |
| ១០-លោក **ប៊ិច សុខែម** | តំណាងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |

ក្រុមការងារនេះមានសិទ្ធិបន្ថែមនូវសមាសភាពមន្ត្រីជំនាញជាជំនួយការតាមសេចក្តីត្រូវការចាំបាច់។

**មាត្រា ៤** : គណៈកម្មការវារីអគ្គិសនីស្ទឹងមេទឹក (មណាម) មានភារកិច្ច :

១-ជំរុញការងារសិក្សាស្រាវជ្រាវកសាងឯកសារបច្ចេកទេស និង សេដ្ឋកិច្ច ស្តីពីគំរោងសាងសង់វារី អគ្គិសនីស្ទឹងមេទឹក (មណាម) ។

២–ធ្វើការចរចាជាមួយភាគីថៃពីលទ្ធភាពនៃការប្រើប្រាស់ និង អភិវឌ្ឍន៍ធនធានរ៉ែក នៃស្ទឹងមេទឹក (មណាម) ដើម្បីជាផលប្រយោជន៍នៃប្រទេសទាំងពីរ ។

៣–ទំនាក់ទំនងស្វែងរកជំនួយពីអង្គការអន្តរជាតិ និងពីបណ្តាប្រទេសនានា ។

៤–ពិនិត្យសិក្សាជ្រើសរើសក្រុមហ៊ុនឯកជនដែលមានលទ្ធភាពធ្វើការសិក្សាស្រាវជ្រាវ បច្ចេកទេសជាបឋម (Prefeasibility study) និងសិក្សាស្រាវជ្រាវអំពី លទ្ធភាពកសាងគំរោង (feasibility study) ។

៥–ពិនិត្យជ្រើសរើសក្រុមហ៊ុនដែលអាចមានលទ្ធភាពធ្វើវិនិយោគក្នុងការងារនេះ ។ រួចធ្វើរបាយការណ៍ពីលទ្ធផលរបស់ខ្លួន ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

**មាត្រា ៥** : ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង និង ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធនិងសាមីជនមានភារកិច្ចទទួល អនុវត្តនូវអនុក្រឹត្យនេះចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្តលេខា និងត្រា** | **ហត្ថលេខា និងត្រា** |
| **នរោត្តម រណប្ញទ្ធិ** | **ហ៊ុន សែន** |

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៦

## អនុក្រឹត្យ លេខ : ១២ អនក្រ.បក

## ស្តីពីការបង្កើតគណៈកម្មការដឹកនាំសំរបសំរួល និង អង្គភាពអនុវត្តគំរោងការស្តារ និងកែលំអអាកាសយានដ្ឋានខេត្តសៀមរាប

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា